INTERNATIONAL MONETARY FUND

**Public Information Notice**

EXTERNAL RELATIONS DEPARTMENT

ការជូនពតិមានជាសាធារណៈ (PIN) លេខ ៧/៩០
សំរាប់ការចែកផ្សាយជាប្រញាប់
៣១ ខែ កក្កដា ២០០៧


មូលនិធិរូបិយវត្ថុអន្តរជាតិ
700 19th Street, NW
Washington, D. C. 20431 USA


# មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បញ្ចប់កិច្ចពិគ្រោះយោបល់ មាត្រាទី IV ឆ្នាំ 2007 ជាមួយប្រទេសកម្ពុជា

នៅថ្ងៃទី 25 កក្កដា 2007 គណៈកម្មការប្រតិបត្តិ (Executive Board) នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបញ្ចប់កិច្ចពិគ្រោះយោបល់មាត្រាទី IV ជាមួយប្រទេសកម្ពុជា [1] ។

## ប្រវត្តិសង្ខេប

គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរឹងមាំអនុញ្ញាតអោយកម្ពុជាអនុវត្តន៏បាននូវកំណើនដ៏គួរអោយកោតសរសើរ និង ធ្វើការទន្ទ្រានលើភាពក្រីក្រ ។ គាំទ្រដោយគោលនយោបាយរូបិយវត្ថុ និង សារពើពន្ធដ៏ប្រុងប្រយ័ត្នដែលពង្រឹងភាពទប់ទល់របស់សេដ្ឋកិច្ចប្រឆាំងនឹងការប៉ះទង្គិចដ៏គំហុកនានា កំណើនជាមធ្យមលើសពី ៩ភាគរយ ចាប់តាំងពីឆ្នាំ ២០០០ បានបង្កើនល្បឿននៅក្នុងប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ។ ដោយចងជាប់មួយផ្នែកដោយក៏រិតដ៏ខ្ពស់ជាងធម្មតានៃដុល្លារូបនីយកម្ម អតិផរណានៅតែស្ថិតនៅទាប ហើយការជឿទុកចិត្តកើនឡើង ។ ទោះបីជាយ៉ាងនេះក៏ដោយ កំណើននៅតែមានមូលដ្ឋានចង្អៀត ពឹងលើវិស័យកាត់ដេរ និង ទេសចរណ៍ ជាមួយវិស័យកសិកម្មដែលគ្រាន់តែរួមចំណែកដោយមានចិរភាពក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ។ អត្រានៃភាពក្រីក្រជាទូទៅបានថយចុះយ៉ាងគួរអោយកត់សំគាល់ ប៉ុន្តែជាមួយនឹងការកើនឡើងនៃវិសមភាព ហើយអត្រានេះនៅតែខ្ពស់នៅតំបន់ជនបទ ។ វឌ្ឍនភាពនឹងត្រូវតែបង្កើនល្បឿន ប្រសិនបើប្រទេសកម្ពុជាត្រូវសំរេចអោយបាននូវគោលដៅអភិវឌ្ឍន៏សហសវត្សរ៍ ។

ការអនុវត្តន៏ម៉ាក្រូសេដ្ឋកិច្ចក្នុងឆ្នាំ2006 បានគួរអោយកោតសរសើរ ។ កំណើនក្នុងឆ្នាំ 2006 មាន 10¾ភាគរយផ្អែក

---

[1] ក្រោមមាត្រាទី IV នៃមាត្រានានារបស់កិច្ចព្រមព្រៀងនៃមូលនិធិរូបិយវត្ថុអន្តរជាតិ មូលនិធិរូបិយវត្ថុអន្តរជាតិតែងតែបើកការពិភាក្សាជាទ្វេភាគីនានាជាមួយសមាជិករាល់មួយឆ្នាំម្តង ។ ក្រុមបុគ្គលិកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ប្រមូលពតិមានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ពិភាក្សាជាមួយមន្ត្រីនានា អំពីគោលនយោបាយ និង ការអភិវឌ្ឍន៏សេដ្ឋកិច្ច ។ ពេលត្រឡប់មកទីចាត់ការកណ្តាល បុគ្គលិករៀបចំរបាយការណ៏មួយ ដែលជាមូលដ្ឋាននៃការពិភាក្សាដោយគណៈកម្មការប្រតិបត្តិ ។ នៅពេលបញ្ចាប់កិច្ចពិភាក្សា នាយកគ្រប់គ្រងដែលជាប្រធាននៃគណៈកម្មការ សង្ខេបទស្សនៈនានារបស់នាយកប្រតិបត្តិទាំងឡាយ ហើយរបាយការណ៏សង្ខេបនេះត្រូវបញ្ជូនទៅរដ្ឋអំណាចរបស់ប្រទេសកម្ពុជា ។ ការជូនពតិមានជាសាធារណៈ (Public Information Notice – PIN) សង្ខេបទស្សនៈទាំងឡាយរបស់គណៈកម្មការប្រតិបត្តិដូចដែលបានបញ្ចេញនៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៧ ដោយផ្អែកលើរបាយការណ៏របស់បុគ្គលិក ។

ទៅលើកំណើនជាបន្តនៃវិស័យកសិកម្មបន្ទាប់ពីផលិតកម្មកសិកម្មដ៏ខ្ពស់បំផុតក្នុងឆ្នាំ 2005 និងការរីកដុះដាលនៃការនាំចេញ។ សំណង់ និង សេវាកម្ម ជាពិសេសវិស័យហិរញ្ញវត្ថុ គាំទ្រសេដ្ឋកិច្ចទីក្រុងដ៏រស់រវើក។ អតិផរណាកើនឡើងបន្តិចនៅពេលថ្មីៗនេះដោយសារតែការឡើងថ្លៃត្រី និង ថ្លៃប្រេង ទោះបីជាយ៉ាងនេះក៏ដោយ អតិផរណាត្រូវសង្ឃឹមថានឹងស្ថិតនៅប្រហែល 4 ភាគរយ ដោយសន្មត់ថាតំលៃប្រេងពិភពលោកមានស្ថេរភាពជាទូទៅ ក្នុងកំឡុងពេលនេះរហូតដល់ដំណាច់ឆ្នាំ ។

ការនាំចេញសំលៀកបំពាក់ និង ទេសចរណ៍កើនឡើងលើសពី 20 ភាគរយក្នុងឆ្នាំ 2006 នៅពេលដែលការនាំចូលបានកើនឡើងដោយសារកំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លា និង តំលៃប្រេងខ្ពស់ បង្កអោយមានឱនភាពគណនីចរន្តក្រៅប្រទេស (ដោយមិនគិតការផ្ទេរផ្លូវការ) ប្រមាណជា 7 ភាគរយនៃផលទុនជាតិ ។ ហិរញ្ញប្បទានក្រៅប្រទេសភាគច្រើនបានមកពីជំនួយ និង ការវិនិយោគបរទេសផ្ទាល់ ដែលបានផ្តោតទៅលើវិស័យកាត់ដេរ ទេសចរណ៍ កសិកម្ម និង សំណង់ ។

គោលនយោបាយសារពើពន្ធនៅតែមានភាពប្រុងប្រយ័ត្នជាបន្ត ។ ឱនភាពសារពើពន្ធជាទូទៅក្នុងឆ្នាំ 2006 នៅតែមានស្ថិរភាព គឺប្រមាណ 3¼ ភាគរយនៃផលទុនជាតិ (ដោយមិនរាប់បញ្ចូលចំណូលលុបបំណុលដែលបានមកពីការកិច្ចផ្តួចផ្តើមលុបបំណុលពហុភាគី - Multilateral Debt Relief Initiative) ។ ការប្រមូលចំណូលបានលើសពីការសង្ឃឹមទុក ជាពិសេសចំណូលមកពីពន្ធក្នុងស្រុក នៅពេលដែលចំណាយត្រូវបានទប់ នេះបានបណ្តាលអោយមានការកើនឡើងបន្ថែមទៀតនូវប្រាក់បញ្ញើធនាគាររបស់រដ្ឋាភិបាល និង ការកាត់បន្ថយដ៏ច្រើននៃ ចំណាយក្នុងស្រុកដែលកកស្ទះ។ និន្នាការនេះបានបន្តក្នុងកំឡុងដើមឆ្នាំ 2007 ។

តំរូវការរូបិយវត្ថុកំពុងបង្កើនល្បឿនដែលជំរុញអោយវិស័យហិរញ្ញវត្ថុដែលមានភាពដុល្លារូបនីយកម្មជាចំបងអោយកើនឡើង ។ រូបិយវត្ថុទូទៅ (Broad Money) កំពុងតែកើនឡើងប្រហែលជា 40ភាគរយ ក្នុងមួយឆ្នាំ ឆ្លុះបញ្ចាំងជាចំបងនូវការកើនឡើងនានានៃប្រាក់បញ្ញើដែលស្ទើរតែទាំងអស់ជាដុល្លា ។ កំចីទៅអោយវិស័យឯកជនដែលជាដុល្លាដែរកំពុងតែរីកដុះដាលលឿនជាងទៀត ប៉ុន្តែក៏វាតនៅតែទាបណាស់ គឺប្រមាណតែ 12ភាគរយនៃផលទុនជាតិប៉ុណ្ណោះ ។

អត្រាប្តូរប្រាក់មានស្ថិរភាព ហើយកំណើននៃទុនបំរុងមានភាពរឹងមាំ ។ ប្រាក់រៀលនៅតែមានស្ថិរភាពជាទូទៅទាំងក្នុងករណីទ្វេភាគី និង ពហុភាគី ជាមួយនឹងការកើនតំលៃបន្តិចនៅដើមឆ្នាំ 2007 ។ ការកើនឡើងនៃតំរូវការរបស់ប្រាក់រៀល មួយផ្នែកដោយសារតែមានភាពល្អប្រសើរក្នុងការគោរពតាមការបង់ពន្ធ បានអនុញ្ញាត្តិអោយធនាគារជាតិនៃកម្ពុជាទិញប្រាក់ដុល្លាពីទីផ្សារបានច្រើនជាងការរំពឹងទុក។ ទុនបំរុងរបស់ធនាគារជាតិនៃកម្ពុជាឥឡូវនេះមានលើសពី 1.2ពាន់លានដុល្លា ទោះបីជាមានការកើនឡើងបន្តិចនៃបំណុលក្រៅប្រទេសដែលកកស្ទះដែលជាប់ទាក់ទងទៅនឹងបំណុលចាស់មិនទាន់ដោះស្រាយរួច ជំពាក់សហរដ្ឋអាមេរិក និង ប្រទេសរុស្ស៊ី ។

ភាពជឿនលឿនមាននៅក្នុងកំណែទំរង់រចនាសម្ព័ន្ធនានា ប៉ុន្តែការងារដែលត្រូវធ្វើនៅមានច្រើនទៀត ។ ការខំប្រឹងប្រែងក្នុងវិស័យសារពើពន្ធ និង ហិរញ្ញវត្ថុកំពុងតែចេញផ្លែផ្កាជាមួយនឹងសមិទ្ធផលដ៏គួរអោយកត់សំគាល់ក្នុងការអនុវត្តន៏នីតិវិធីចំណាយ និង គណនេយ្យរដ្ឋាភិបាលថ្មី ពង្រឹងបទបញ្ញត្តិប្រុងប្រយ័ត្ននានាសំរាប់វិស័យធនាគារ ។ ទោះបីជាយ៉ាងនេះក្តី វឌ្ឍនភាពក្នុងការកែទំរង់ច្បាប់ និង តុលាការមានភាពយឺតជាងច្រើន ។ កិច្ចខំប្រឹងប្រែងដើម្បីពង្រឹងពង្រាងច្បាប់ប្រឆាំងអំពើពុករលួយត្រូវបានជាប់គាំងរង់ចាំការពិនិត្យនៃក្រុមព្រហ្មទណ្ឌ ហើយការិយាល័យប្រឆាំងនឹងអំពើពុករលួយនៅឯក្រុមប្រឹក្សារដ្ឋមន្ត្រីបានបង្កើតឡើងក្នុងដំណាក់កាលបណ្តោះអាសន្ន ។ ច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភារវកម្ម និង ច្បាប់គយបានអនុម័តរួចសព្វគ្រប់ ប៉ុន្តែពង្រាងនៃច្បាប់ក្ស័យធន និង ពង្រាងច្បាប់អំពីលក្ខន្តិកៈចៅក្រមនិងរាជអាជ្ញាកំពុងតែត្រូវបានពិភាក្សានៅថ្នាក់ក្រសួងនៅឡើយ ។

## ការវាយតំលៃរបស់គណៈកម្មការប្រតិបត្តិ

បណ្ណានាយកប្រតិបត្តិបានកោតសរសើររដ្ឋអំណាចកម្ពុជា ចំពោះគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏រឹងមាំរបស់កម្ពុជា ដែលបានជំរុញអោយមានកំណើនយ៉ាងឆាប់រហ័សជាមួយនឹងស្ថិរភាពទាំងក្នុង និង ក្រៅស្រុក ហើយបានអនុញ្ញាត្តិអោយមានការទន្រ្ទានទៅលើភាពក្រីក្រ ។ ស្ថានភាពសារពើពន្ធរបស់កម្ពុជាមានភាពរឹងមាំ បំណុលសាធារណៈ និង បំណុលក្រៅប្រទេសមានចិរភាព និង អតិផរណានៅតែទាប ។ ដើម្បីកែលំអអោយមានភាពសំបូរបែបនៃប្រភពនានារបស់កំណើន និង កាត់បន្ថយភាពក្រីក្រដោយចិរភាព បណ្ណានាយកប្រតិបត្តិបានលើកទឹកចិត្តអោយរដ្ឋអំណាចកម្ពុជាធ្វើអោយប្រសើរនូវសេវាសាធារណៈ វិស័យហិរញ្ញវត្ថុ និង បរិស្ថានធ្វើអាជីវកម្ម រួមទាំងដោយការពង្រឹងអភិបាលកិច្ចផងដែរ ។

បណ្ណានាយកប្រតិបត្តិកោតសរសើរការប្តេជ្ញាចិត្តរបស់រដ្ឋអំណាចកម្ពុជា ក្នុងការបន្តគោលនយោបាយសារពើពន្ធប្រុងប្រយ័ត្ន ដោយជៀសវាងហិរញ្ញប្បទានក្នុងស្រុកដោយធនាគារ នៅពេលដែលមានការកែលំអកំរិត និង គុណភាពនៃចំនូលនិងចំណាយ។ បណ្ណានាយកប្រតិបត្តិបានស្វាគមន៏ ចំពោះគោលបំណងរបស់អាជ្ញាធរដើម្បីតំរង់ទិសចំណាយសាធារណៈឆ្ពោះទៅរកគោលដៅនៃផែនការអភិវឌ្ឍន៏យុទ្ធសាស្រ្តជាតិ ជាមួយនិងទស្សនៈមួយដើម្បីដោះស្រាយភាពក្រីក្រជនបទ។ នាយកប្រតិបត្តិបានលើកទឹកចិត្តដល់រដ្ឋអំណាចក្នុងការបង្កើនចំណាយដើម្បីកាត់បន្ថយភាពក្រីក្រប្រកបដោយគុណភាពខ្ពស់រួមទាំងការវិនិយោគមូលធនប្រកបដោយផលិតភាព។ ពួកគាត់បានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការតំឡើងប្រាក់បៀវត្សសំរាប់វិស័យសាធារណៈដើម្បីកែលំអសេវាសាធារណៈ និង បន្ទុចបង្អាក់អំពើពុករលួយ ក្នុង

ពេលជាមួយនោះ បានសង្កត់ធ្ងន់ចំពោះតំរូវការនៃការដាក់គោលនយោបាយប្រាក់បៀវត្សនៅក្នុងយុទ្ធសាស្រ្តកំណែទំរង់សេវាសាធារណៈជាទូទៅមួយ ។

បណ្តានាយកប្រតិបត្តិបានស្វាគមន៍ចំពោះការរីកចំរើនថ្មីៗនេះ នៅក្នុងកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានពង្រឹងដំណើរការថវិកានិងបង្កើតនូវមូលដ្ឋានគ្រឹះសំរាប់ការចំណាយដ៏មានប្រសិទ្ធភាពជាងមុន ។ នាយកប្រតិបត្តិបានកត់សំគាល់ អំពីសារៈសំខាន់នៃការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និង អត្តសញ្ញាណកម្មចំណាយជាអាទិភាពក្នុងថវិកាឆ្នាំ 2008 ។

បណ្តានាយកប្រតិបត្តិបានចាត់ទុកថា ដើម្បីសំរេចនូវទិសដៅគោលនយោបាយចំណាយ តំរូវអោយមានការកើនឡើងនៃចំណូលដោយចិរភាព ។ការកើនឡើងនៃការប្រមូលពន្ធដ៏គួរអោយកោតសរសើរថ្មីៗនេះដែលទទួលបានដោយការកែលំអរដ្ឋបាលត្រូវបានទទួលស្គាល់។ ទោះជាយ៉ាងនេះក៏ដោយ វិធានការណ៏គោលនយោបាយដើម្បីពង្រីកមូលដ្ឋានពន្ធ និង កែលំអរចនាសម្ព័ន្ធនៃប្រព័ន្ធពន្ធដារត្រូវតែមានជាបន្ត។ នាយកប្រតិបត្តិបានលើកទឹកចិត្តដល់រដ្ឋអំណាចកម្ពុជាដើម្បីអនុវត្តជំហានដំបូងនានាអោយបានឆាប់បើអាចធ្វើបាន។

បណ្តានាយកប្រតិបត្តិបានចាត់ទុកគោលនយោបាយប្តូរប្រាក់បច្ចុប្បន្ននេះរបស់កម្ពុជាថាសមស្រប ។ នាយកប្រតិបត្តិបានកត់សំគាល់អំពីការវាយតំលៃដែលថា តំលៃនៃប្រាក់រៀលគឺសមស្របជាមួយនឹងមូលដ្ឋានគ្រឹះក្នុងដំណាក់កាលមធ្យម ហើយថាមូលដ្ឋាននៃគណនីចរន្តក្រៅប្រទេសស្ថិតនៅក្នុងចំណុចលំនឹង (Equilibrium)។ ដោយសារតែតំរូវការដើម្បីបំពេញបន្ថែមទុនបំរុងបរទេស ប្រសិនបើមានសម្ពាធនៃការចុះតំលៃរបស់ប្រាក់រៀលដោយចិរភាព សម្ពាធនោះនឹងមិនត្រូវរារាំងទេ ។

បណ្តានាយកប្រតិបត្តិបានគាំទ្រមធ្យោបាយរូបិយវត្ថុសំរបសំរួលរបស់ធនាគារជាតិកម្ពុជា ប៉ុន្តែដាស់តឿនអោយប្រុងប្រយ័ត្នចំពោះការប្រែប្រួលក្នុងពេលអនាគតនៃប្រាក់បៀវត្ស និង តំលៃ ដែលត្រូវតែតាមដាន ដើម្បីបញ្ចៀសពីសម្ពាធនៃអតិផរណា ។ នាយកប្រតិបត្តិបានកត់សំគាល់ថា អត្ថប្រយោជន៍នៃដុល្លារូបនីយកម្មដែលជាមូលដ្ឋានសំរាប់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជា និង ការរីកដុះដាលវិស័យហិរញ្ញវត្ថុ នៅតែធំជាងគុណវិបត្តិនានាដែលកើតមកអំពីការបាត់បង់ចំណេញពីការបោះពុម្ពប្រាក់ (Seignorage) និង ការរាំងខ្ទប់ដល់ការប្រើប្រាស់គោលនយោបាយរូបិយវត្ថុដ៏សកម្មមួយ ។ ក្នុងកំណាក់កាលវែង ហើយបើមានលក្ខខ័ណ្ឌសមត្ថភាព និង គោលនយោបាយសមស្រប ការប្រើប្រាស់ប្រាក់រៀលច្រើនជាងមុននឹងជួយពង្រឹងប្រសិទ្ធិភាពនៃគោលនយោបាយរូបិយវត្ថុ។

បណ្ដានាយកប្រតិបត្តិបានអំពាវនាវដល់ រដ្ឋអំណាចកម្ពុជា អោយពង្រឹងការគ្រប់គ្រងធនាគារ និង ធ្វើអោយមានការប្រតិបត្តិយ៉ាងតឹងរឹងតាមបទបញ្ញត្តិប្រុងប្រយ័ត្ន ដើម្បីធានាថា វិស័យហិរញ្ញវត្ថុ នៅតែបន្តចូលរួមចំណែកធ្វើអោយមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ បណ្ដានាយកប្រតិបត្តិបានលើកទឹកចិត្តដល់ រដ្ឋអំណាចកម្ពុជាអោយធ្វើការជាមួយធនាគារពាណិជ្ជទាំងឡាយ ដើម្បីពង្រឹងប្រព័ន្ធទូទាត់ និង សំរួលអន្តរការីកម្មហិរញ្ញវត្ថុ ហើយបានស្វាគមន៏នូវការអនុម័តនៃច្បាប់ប្រឆាំងនឹងការសំអាតប្រាក់ថ្មីៗនេះ។

បណ្ដានាយកប្រតិបត្តិបានស្វាគមន៏ចំពោះការប្ដេជ្ញាចិត្តរបស់រដ្ឋអំណាចកម្ពុជា ដូចបានបង្ហាញអោយឃើញដោយការបង្កើតនូវការិយាល័យប្រឆាំងនឹងអំពើពុករលួយនៅឯក្រុមប្រឹក្សារដ្ឋមន្ត្រី។ នាយកប្រតិបត្តិបានគូសបញ្ជាក់ថា បន្តការកែលំអអភិបាលកិច្ចមានសារៈសំខាន់ណាស់ដើម្បីធ្វើអោយប្រសើរនូវបរិស្ថានអាជីវកម្ម និង ពង្រឹងការប្រមូលចំណូលព្រមទាំងលើកដំកើនប្រសិទ្ធភាពនៃចំណាយ ។ បណ្ដានាយកប្រតិបត្តិបានលើកទឹកចិត្តដល់អាជ្ញាធរអោយការបង្កើតនូវនីតិកម្មដ៏ត្រឹមត្រូវស្តីអំពីការប្រឆាំងអំពើពុករលួយ និង អោយកែលំអការគ្រប់គ្រងទ្រព្យ និង សម្បទានទាំងឡាយរបស់រដ្ឋ ។

បណ្ដានាយកប្រតិបត្តិបានសង្កេតឃើញថា ផលិតកម្មប្រេងឥន្ធនៈនឹងកែលំអចក្ខុវិស័យនានាបាន តែវាក៏នាំមកនូវភាពប្រឈមផ្សេងៗបន្ថែមទៀតដែរ ដើម្បីធានាអោយមានតុល្យភាពសមស្រប រវាងការសន្សំ ការវិនិយោគ និង ការប្រើប្រាស់អនាគតចំណូលពីប្រេង។ បណ្ដានាយកប្រតិបត្តិបានស្វាគមន៏ការទទួលស្គាល់របស់រដ្ឋអំណាចកម្ពុជាថា ក្របខ័ណ្ឌច្បាប់ច្បាស់លាស់ និង ពង្រឹងរបបពន្ធ សំរាប់វិស័យប្រេងមានសារៈសំខាន់ណាស់។ បណ្ដានាយកប្រតិបត្តិបានលើកទឹកចិត្តអោយរដ្ឋអំណាចកម្ពុជាអនុម័តគំនិតផ្ដួចផ្ដើមតម្លាភាពនៃឧស្សាហកម្មទាញយកធនធាន (EITI)។

បណ្ដានាយកប្រតិបត្តិបានស្វាគមន៏ចំពោះការអត់ធ្វត់មិនធ្វើកិច្ចសន្យាកំចីដែលមិនមានលក្ខណៈសម្បទាន បន្ទាប់ពីមានការចាត់ថ្នាក់ឥណទានអធិបតេយ្យរបស់កម្ពុជាដែលទទួលបានថ្មីៗនេះ។ បណ្ដានាយកប្រតិបត្តិបានអំពាវនាវដល់អាជ្ញាធរអោយបន្តគោលនយោបាយកំចីយ៉ាងប្រុងប្រយ័ត្នបច្ចុប្បន្ន ដែលធានារចនាសម្ព័ន្ធសម្បទានដ៏ខ្ពស់នៃបំណុលបរទេសដែលគាំពារចិរភាពបំណុល។

បណ្ដានាយកប្រតិបត្តិបានលើកទឹកចិត្តដល់អាជ្ញាធរក្នុងការបន្តខំប្រឹងប្រែងដោះស្រាយបំណុលយឺតយ៉ាវដែលនៅសេសសល់ជាមួយម្ចាស់បំណុលផ្លូវការនានា ដោយកត់សំគាល់ថាការដោះស្រាយដោយជោគជ័យមួយនឹងបើកផ្លូវដល់ការពិចារណាលើកិច្ចព្រមព្រៀងនៃកម្មវិធីឥណទានគាំទ្រកំណើននិងការកាត់បន្ថយភាពក្រីក្រ (PRGF) ថ្មីមួយ។ នាយកប្រតិបត្តិបានស្វាគមន៏ចំពោះគោលនយោបាយជាប់ទាក់ទិនដ៏ខ្លាំងក្លាមួយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិជាមួយកម្ពុជា រួមទាំងតាមរយៈការផ្ដល់ជំនួយបច្ចេកទេស។

## Table 1. Cambodia: Selected Economic Indicators, 2004–07

Nominal GDP (2006): $7254 million
GDP per capita (2006): $513
Population (2006): 14.2 million

| | 2004 | 2005 | 2006 Est. | 2007 Proj. |
|---|---|---|---|---|
| **Real economy** | (annual growth rates, in percent) | | | |
| Real GDP | 10.0 | 13.5 | 10.8 | 9.1 |
| Real GDP excluding agriculture | 15.2 | 8.7 | 17.0 | 11.3 |
| CPI Inflation (end of period) | 5.6 | 6.7 | 2.8 | 3.8 |
| | (in percent of GDP) | | | |
| Domestic investment | 17.7 | 20.1 | 21.5 | 21.5 |
| Government investment | 6.0 | 5.6 | 5.5 | 5.3 |
| National saving | 15.6 | 15.8 | 19.5 | 19.5 |
| **Money and credit** | (annual growth rates in percent, unless otherwise indicated) | | | |
| Broad money | 30.4 | 16.1 | 38.2 | 42.9 |
| Net credit to the government 1/ | -2.4 | -4.9 | -10.6 | -0.6 |
| Private sector credit | 35.9 | 31.8 | 51.6 | 44.7 |
| **Government operations** | (in percent of GDP) | | | |
| Revenue 2/ | 10.3 | 10.3 | 11.5 | 10.8 |
| Expenditure | 14.9 | 13.7 | 13.5 | 13.9 |
| Overall budget balance 2/ | -4.6 | -3.4 | -2.0 | -3.1 |
| Foreign financing, net | 4.7 | 4.8 | 4.4 | 3.8 |
| Domestic financing 3/ | -0.2 | -1.5 | -2.5 | -0.7 |
| **Balance of payments** | (in millions of dollars, unless otherwise indicated) | | | |
| Exports | 2,589 | 2,910 | 3,693 | 4,313 |
| Imports | -3,269 | -3,928 | -4,749 | -5,526 |
| Current account (excl. official transfers) | -436 | -591 | -525 | -587 |
| (in percent of GDP) | -8.2 | -9.4 | -7.2 | -7.0 |
| Overall balance | 49 | 65 | 193 | 246 |
| Gross official reserves | 809 | 915 | 1,097 | 1,400 |
| (in months of imports of goods and non-factor services) | 2.6 | 2.4 | 2.4 | 2.6 |
| (in percent of uncovered dollar deposits in banks) 4/ | 179 | 146 | 113 | 90 |
| Public external debt 5/ | 2,043 | 2,123 | 2,248 | 2,464 |
| (in percent of GDP) | 38.5 | 33.9 | 31.0 | 29.5 |
| **Memorandum items:** | | | | |
| Nominal GDP (in billions of riels) | 21,343 | 25,693 | 29,809 | 33,822 |
| (in millions of U.S. dollars) | 5,308 | 6,271 | 7,254 | ... |
| Exchange rate (riels per dollar; end of period) | 4,031 | 4,116 | 4,046 | ... |

Sources: Data provided by the Cambodian authorities; and Fund staff estimates and projections.

1/ Contribution to broad money growth.
2/ In 2006, includes transfer of MDRI proceeds as capital revenue transfer .
3/ Includes funds in transit and payment orders in excess of cash released.
4/ Dollar deposits in commercial banks net of their unrestricted reserves at NBC.
5/ From January 2006 includes the impact of debt forgiveness from the IMF under the MDRI.